# ចំណាប់អារម្មណ៍

## ដោយ:លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

## កាលបរិច្ឆេទ៖ ថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៩

## ទីកន្លែង: សាលសន្និសិទចតុមុខ

## ឱកាស៖ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩

សូមគោរព

- ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ តំណាងនៃរាជរដ្ឋាភិបាល និងក្រសួងនានា
- ដៃគូអភិវឌ្ឍន៍
- អង្គការសង្គមស៊ីវិល សហគមន៍អ្នករស់នៅជាមួយមេរោគអេដស៍ និងប្រជាជនប្រឈមមុខខ្ពស់

ក្នុងនាមក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយមានវត្តមាននៅទីនេះ ជាមួយអ្នកទាំងអស់គ្នានាថ្ងៃនេះ ដើម្បីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩ ។

កាលពីពីរទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាមានការរីករាលដាលយ៉ាងឆាប់រហ័សនៃមេរោគអេដស៍។ នៅត្រឹមឆ្នាំ ២០១៧ ប្រទេសកម្ពុជា បានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសទាំង ៧ នៅលើពិភពលោកដែលសម្រេចបានគោលដៅ ៩០-៩០-៩០ (៩០ ភាគរយនៃអ្នករស់នៅជាមួយមេរោគ អេដស៍ដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ; ៩០ ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ដែលបានដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ទទួលការព្យាបាលដោយឱសថប្រឆាំងនឹង មេរោគ

អេដស៍ និង៩០ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ដែលទទួលបានការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ត្រូវបានបង្ក្រាបមេរោគឱ្យនៅកម្រិតទាប)។

នៅចន្លោះឆ្នាំ ២០១០ និង ២០១៨ ការឆ្លងថ្មីនៃមេរោគអេដស៍បានធ្លាក់ចុះ ៦២ ភាគរយ និងការស្លាប់ទាក់ទងនឹងជំងឺអេដស៍បានធ្លាក់ចុះ ៤៨ ភាគរយ។ ប្រទេសកម្ពុជាបានផ្លាស់ប្តូរការរីករាលដាលមេរោគអេដស៍របស់ខ្លួន ដោយសារការផ្តោតលើគោលនយោបាយ និងកម្មវិធីលើប្រជាជន។

សព្វថ្ងៃនេះតាមការប៉ាន់ស្មាន មានអ្នករស់នៅជាមួយមេរោគអេដស៍ប្រមាណជា ៧៣,០០០ នាក់នៅប្រទេសកម្ពុជា ក្នុងនោះ ៨១ ភាគរយកំពុងទទួលការព្យាបាលសង្គ្រោះជីវិតដោយឱសថប្រឆាំងនឹងមេរោគអេដស៍ និង ៧៨ ភាគរយត្រូវបានបង្ក្រាបមេរោគឱ្យនៅកម្រិតទាប។

អ្នករស់នៅជាមួយមេរោគអេដស៍មិនអាចចម្លងមេរោគអេដស៍ ទៅអ្នកដទៃបានទេ ប្រសិនបើពួកគេនៅបន្តការព្យាបាល ហើយបន្ទុកមេរោគអេដស៍របស់ពួកគេត្រូវបានបង្ក្រាបដោយជោគជ័យដល់កម្រិតដែលមិនអាចរកឃើញក្នុងឈាម ដែលត្រូវបានគេស្គាល់ថា មិនអាចរកឃើញបន្ទុកមេរោគ អេដស៏ = មិនអាចចម្លងមេរោគអេដស៍បាន។

សមិទ្ធិផលដ៏ធំធេងទាំងនេះ គឺជាលទ្ធផលនៃការប្តេជ្ញាចិត្តនិងការដឹកនាំផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ភាពជាដៃគូដ៏រឹងមាំជាមួយកាកបាទក្រហមកម្ពុជា អង្គការសង្គមស៊ីវិល អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ និងការចូលរួមយ៉ាងសកម្មរបស់សហគមន៍អ្នករស់នៅជាមួយមេរោគ អេដស៍ និង ប្រជាជនប្រឈមមុខខ្ពស់។

ទោះបីជាមានសមិទ្ធិផលដ៏ធំធេងទាំងនេះក៏ដោយ ក៏ការរីករាលដាលនៃជំងឺអេដស៍នៅមិនទាន់ចប់នៅឡើយទេ។

មេរោគអេដស៍បន្តជះឥទ្ធិពលដល់ក្រុមប្រជាជនមួយចំនួនដែលត្រូវបានគេស្គាល់ថាជាក្រុមប្រជាជនប្រឈមមុខខ្ពស់ ជាងប្រជាជនដទៃទៀត។ ក្រុមប្រជាជនប្រឈមមុខខ្ពស់ទាំងនេះ រួមមានស្ត្រីធ្វើការតាមគ្រឹះស្ថានកំសាន្ត បុរសរួមភេទជាមួយបុរស អ្នកចាក់គ្រឿងញៀន និងស្ត្រីប្លែងភេទ។ ក្នុងឆ្នាំ ២០១៨ កន្លងទៅ ២៥ ភាគរយនៃការឆ្លងថ្មីនៃមេរោគអេដស៍ គឺស្ថិតក្នុងចំណោមបុរសរួមភេទជាមួយបុរស ដែលជាការកើនឡើងច្រើនជាងបីដងពីចំនួន ៧ ភាគរយកាលពីឆ្នាំ ២០១០។ តាមការប៉ាន់ស្មាននៅថ្នាក់ក្រោមជាតិ បានបង្ហាញថារៀងរាល់ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ថ្មីចំនួន ៣ នាក់ គឺមាន

១នាក់ស្ថិតក្នុងរាជធានីភ្នំពេញ។ ខេត្តចំនួន ៦ (ភ្នំពេញ បាត់ដំបង សៀមរាប កំពង់ចាម បន្ទាយមានជ័យ និងតាកែវ) គ្របដណ្តប់ចំនួន ៧០ ភាគរយនៃការឆ្លងថ្មីនៃមេរោគអេដស៍ទាំងអស់នៅក្នុងប្រទេសកម្ពុជា។

ប្រទេសកម្ពុជាបានផ្តល់នូវសេវាបង្ការ ថែទាំ និងការព្យាបាលដោយផ្អែកលើភស្តុតាងអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ទាំងនេះបានបង្កើតបរិយាកាសគាំទ្រនៅតាមមូលដ្ឋានសុខាភិបាល និងតាមកន្លែងសហគមន៍។ ប៉ុន្តែនៅតែមានតម្រូវការជាបន្ទាន់សម្រាប់ជម្រើស និងធ្វើឱ្យប្រសើរឡើងនូវការបង្ការមេរោគអេដស៍ប្រកបដោយប្រសិទ្ធិភាព ជាពិសេសសម្រាប់ប្រជាជនប្រឈមមុខខ្ពស់វ័យក្មេង រួមបញ្ចូលទាំង ការលេបថ្នាំបង្ការជាមុននៅពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ (PrEP) និងការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង។

*ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស មិត្តសហគមន៍ទាំងអស់ជាទៅមេត្រី!*

ប្រធានបទសកលនៃទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំនេះ គឺ" សហគមន៍ធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន" ។

សហគមន៍រាប់បញ្ចូល ទាំងមិត្តភក្តិ អ្នកចុះអប់រំផ្ទាល់ អ្នកផ្តល់ប្រឹក្សា អ្នកផ្តល់សេវាសុខភាពសហគម បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ ឬរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ដូចជាស្ត្រីធ្វើការតាមគ្រឹះស្ថានកំសាន្ត បុរសរួមភេទជាមួយបុរស ស្ត្រីប្លែងភេទ អ្នកចាក់គ្រឿងញៀន ស្ត្រីនិងមនុស្សវ័យក្មេង អង្គការសង្គមស៊ីវិល និងសកម្មជននៅថ្នាក់មូលដ្ឋានជាដើម។

សហគមន៍គឺជាភ្នែក ត្រចៀក និងបេះដូងនៃការឆ្លើយតបនឹងជំងឺអេដស៍ និងជាគន្លឹះក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប៉ុន្តែជាញឹកញាប់មានការខ្វះខាតធនធាន និងខ្វះការទទួលស្គាល់ដែលពួកគេសមនឹងទទួលបាន និងត្រូវការ។ការដឹកនាំ និងការតស៊ូមតិរបស់ពួកគេធានាថាការឆ្លើយតបនឹងជំងឺអេដស៍នៅតែមានភាពពាក់ព័ន្ធ និងមានមូលដ្ឋាន យកមនុស្សជាមជ្ឈមណ្ឌលនិងមិនទុកនរណាម្នាក់ចោលឡើយ។

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ផ្តល់នូវវេទិកាដ៏សំខាន់មួយ ដើម្បីបង្ហាញពីតួនាទីរបស់សហគមន៍នៅពេលដែលថវិកាត្រូវបានកាត់បន្ថយ ដែលកំពុងធ្វើឱ្យនិរន្តរភាពនៃសេវា និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ ស្ថិតក្នុងហានិភ័យ។

តាមរយៈការចុះហត្ថលេខាលើសេចក្តីប្រកាសនយោបាយរបស់អង្គការសហប្រជាជាតិឆ្នាំ ២០១៦ ស្តីពីការបញ្ចប់ការរីករាលដាលជំងឺអេដស៍ ប្រទេសទាំងឡាយបានបញ្ជាក់ពីតួនាទីសំខាន់ ដែលសហគមន៍ដើរតួក្នុងការតស៊ូមតិ ការចូលរួមក្នុងការឆ្លើយតបនឹងជំងឺអេដស៍ និងការផ្តល់សេវា។ លើសពីនេះទៅទៀត ពួកគេបានទទួលស្គាល់ថាការឆ្លើយតបរបស់សហគមន៍ចំពោះមេរោគអេដស៍ត្រូវតែពង្រីក និងប្តេជ្ញាយ៉ាងហោចណាស់ ៣០ ភាគរយនៃសេវាមេរោគអេដស៍ គួរតែត្រូវបានដឹកនាំដោយសហគមន៍នៅឆ្នាំ ២០៣០ ។

បន្តភាពជាអ្នកដឹកនាំនយោបាយដ៏រឹងមាំ និងភាពជាដៃគូជាមួយសហគមន៍អ្នករស់នៅជាមួយមេរោគអេដស៍ និងប្រជាជនប្រឈមមុខខ្ពស់ គឺជាមធ្យោបាយតែមួយគត់ ដើម្បីឱ្យការបញ្ចប់ការរីករាលដាលជំងឺអេដស៍អាចក្លាយជាការពិត។

សហគមន៍របស់យើង គឺជាប្រភពនៃកម្លាំង ហើយពួកគេបង្ហាញពីសក្តានុពលដែលមិនទាន់ត្រូវបានបញ្ចេញ។ ការបញ្ចេញសក្តានុពលទាំងនោះ គឺជាគន្លឹះដើម្បីទទួលបានសន្ទុះដែលយើងត្រូវការ ដើម្បីធ្វើឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័ស ឆ្ពោះទៅរកការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការធ្វើឱ្យមាននិរន្តរភាពលើការគ្រប់គ្រងការរីករាលដាលជំងឺអេដស៍ និងឆ្ពោះទៅរកមាគ៌ាត្រឹមត្រូវដើម្បីបញ្ចប់ការរីករាលដាលជំងឺអេដស៍នៅឆ្នាំ ២០២៥ ។

កាលណាយើងវិនិយោគកាន់តែច្រើនទៅលើសហគមន៍ យើងកាន់តែខិតជិតដល់ទីបញ្ចប់នៃការរីករាលដាលនៃជំងឺអេដស៍។

សូមអរគុណ!